# ផ្កាស្រពោន

## ភាគទី១០

ព្រះសុរិយារះទន្ទេងចាំងចុងដូងលៃ ដែលមានវាយោមកបន្ទន់យោលយាលទៅមក។ អ្នកផងទាំងឡាយដើរហូរហែចុះឡើងពាសពេញ។ យាយនួននិងម៉ែផៃស្ទៀកពាក់ស្អាតបាត នាំនាងវិធាវីដែលមានសាច់ស្ងាំង ហើយដណ្ដប់ក្រមា ដើរលុយទឹកឆ្វងស្ទឹងទៅផ្សារ។ ស្ទឹងសង្កែនៅរដូវប្រាំង តែងរីងស្រកស្ទើរអស់នៅសល់តែខ្សែទឹកតូចតាមប្រឡោះកូនកោះខ្សាច់ដុះឡើងក្នុងផ្ទៃនៃទឹក។ ដោយសារក្រុងបាត់ដំបងមិនសូវសំបូរទៅដោយស្ពាន និងដោយសារទឹករាក់ពេករកប្រើទូកដមិនកើត មហាជនតែងនាំគ្នាលាត់សំពត់លុយឆ្លងកាត់ទៅ ពីត្រើយម្ខាងទៅត្រើយម្ខាង។

គ្រានោះមានឈ្នួលម្នាក់លីវ៉ាលីស ស្បែកមួយធំនៅលើស្មាឆ្វេង និងយួរកូនវ៉ាលីសតូចមួយនៅដៃស្ដាំដើរតាមក្រោយស្ត្រីទាំងបីប្រាណ។ នាងវិធាវីខំប្រឹងទប់ខ្លួនកុំឲ្យដួលដោយកំលាំងទឹកហូរច្រាន។ ដំណើរនាងក៏ឆេងឆោងទ្រេតមិនដូចជាជន ដែលលុយទឹកជាមួយនាងហើយដែលមានអាយុច្រើនជាងនាងនោះឡើយ។ មុខស្ទេកស្ងាំង និងដំណើរបែបនេះជាហេតុចង្អុលឲ្យឃើញថា នាងមានសុខភាពមិនមាំទាំទេ។

កាលបើបានដល់ផ្សារវិលហើយ យាយនួនគាត់តំរង់ទៅចំណតឡានទៅសៀមរាប។ លុះបានតថ្លៃរួចគាត់ក៏បង្គាប់ឲកូនគាត់និងម៉ែផៃឡើងជិះលើរថយន្តនោះ។ លុះគាត់ប្រាប់ឲ្យគូលីឡានម្នាក់ លើកវ៉ាលីសទាំងពីររៀបដាក់ទៅលើដំបូលរថយន្តឲ្យបានស្រួលបួលឲ្យគាត់រួច ទើបគាត់ដើរទៅរកទិញម្ហូបចំណីយកទៅទុកអាស្រ័យ

យីចៃតើហ្ន៎! អញ្ជើញទៅណាមកណាបានជាទិញអីវ៉ាន់យ៉ាងនេះ? យាយនួនគាត់ងើបមើលឡើងឃើញនាងថូ គាត់ក៏ញញឹមឆ្លើយ:

ចាំនាង ខ្ញុំជូនកូនទៅសៀមរាប។

បើយ៉ាងនេះ ចាំឲ្យគេបើកឡានតូចខ្ញុំជូនទៅ! កុំជិះឡានឈ្នួលធ្វើអី វាពិបាកណាស់។

អរណាស់ហើយនាង ខ្ញុំទិញកន្ទែងស្រេចទៅហើយកុំឲ្យនាងព្រួយ។

អត្ថបទដោយ៖ មាស សុភាព

មានកើតអីចែ ឡានខ្ញុំនៅទំនេរសោះ ប៉ុនជាទៅលេងជាមួយគ្នាទេតើ។

ចិត្តយាយនួនចង់ទទួលអាការគួរសមនៃជនទួងគាត់ពន់ពេកតែគាត់នឹកខ្លាចទាស់ចិត្តកូនគាត់។ គាត់ក៏នៅស្ងៀមមិនតប ហើយលូកដៃទៅរើសសាច់ក្រកឲ្យចិនថ្មីងចំនួនកន្លះនាឡិ។ ឲ្យនាងថូទៅឈរចាំមើល។ លុះឃើញយាយនួនទិញរួចហើយ ក៏ចៅពៅសួរថែមទៀត:

ឯណា ក្មួយ ចែ?

វានៅចាំឡានឯនោះ។

បើអីចឹង ខ្ញុំទៅជួបមួយភ្លែត។

ថាហើយ ស្ត្រីទាំងពីរនាក់ក៏នាំគ្នាដើរត្រង់ទៅឡានឈ្នួល:

យី ក្មួយឯងទៅលេងសៀមរាបហ្នឹង?

នាងវិធាវី ដែលភ្នែករវល់សំឡឹងក្ដីកទៅឆ្ងាយ លុះឮសំដីនេះហើយក៏ភ្ញាក់ខ្លួនព្រើត។ នាងងាកមុខមកឃើញនាងថូ កត្រូនាងដែលពីមុនស្លាំងសដូចទេសឯក ក៏ប្រែជាក្រហមទុំភ្លាមដោយសេចក្ដីក្រៅក្រហាយ។ តាំងតែពីនាងដឹងខ្លួនថាម្ដាយនាងលើកឲ្យទៅជាកូនប្រសានាងថូ កាលណាមកនាងចេះតែទោម្នេញដំណេកមិនបាន បាយទឹកអ្វីក៏ឡើងជាប្រហាតឥតឱជារស។ នាងដែលមិនហ៊ាន នឹកខឹងនឹងមាតាក៏បង្វិលសេចក្ដីក្រោធនេះដាក់ទៅលើគ្រួសារដែល ប្រាថ្នាចង់បាននាងជាកូនប្រសារវិញ។ យាយនួនឃើញកូនគាត់ចេះតែមុខស្រពោន ហើយស្គមថយកម្លាំងទៅៗ ដូច្នោះក៏គិតឃើញថាគួរនាំកូនគាត់ទៅលេង រំហើយចិត្ត ដោយយល់ថាការទស្សនាបុរាណដ្ឋានទាំងពួងដែលឋិតនៅក្នុងខេត្តសៀមរាប នឹងអាចនាំឲ្យកូនគាត់រីករាយសប្បាយ មានសាច់មានឈាមឡើង នឹងអាលរៀបការឲ្យទាន់ខែពិសាខខាងមុខ។

នាងវិធាវីដែលឈ្វេងយល់គំនិត កំបាំងម្ដាយខ្លួនដូច្នោះ ក៏រឹតតែក្នាញ់តែមិនចេញស្ដីថាអ្វីឡើយ។ លុះឮសំដីនាងថូមកប្រលោមសួរទៀត សេចក្ដីក្រោធពិរោធទាំងប៉ុន្មាន ក៏ដាលពុះពោរឡើងពេញទាំងទ្រូង តែដោយនាងជាអ្នកមានពូជពង្សនាងក៏ខំទប់សង្កត់ហើយឆ្លើយតបដោយសំឡេងនៅញ័របន្តិច។

ចា៎ះមីង ម៉ែគាត់នាំខ្ញុំទៅលេងអង្គរ។

អត្ថបទដោយ៖ មាស សុភាព

យីក្មួយ! ឯងកើតអីហ្នឹងក៏ស្គមម្ល៉េះ? មកកុំជុះឡាននេះ ចាំជិះឡានមីងវិញ មីងប្រើឲ្យទៅយកមួយរំពេចបានហើយ។

អរគុណណាស់ហើយមីង កុំឲ្យមីងមានព្រួយឡើយ ម្យ៉ាងទៀតខ្លួនខ្ញុំនេះមិនមានរោគអ្វីទេ។ នាងថូរៀបនឹងហាមាត់ឆ្លើយទៅហើយ ប៉ុន្តែជួនជាពេលនោះ មានមនោគតិមួយចំឡែក ហើរមកប៉ះសតិគាត់ គាត់ក៏ឈប់នៅស្ងៀមទៅវិញ។ មួយសន្ទុះក្រោយមកនាងថូក៏លាអ្នកដំណើរទាំងនោះ ក៏ចេញទៅ។ ឡានរត់លឿន...រត់លឿនកាត់វាលស្រែដែលមានជញ្ជ្រាំងជាប់នៅដី នាងវិធារីដែលមានម្ដាយនាង និងម៉ែផែអង្គុយអមសងខាងនាង ខំគយគន់រុក្ខជាតិ ជួរភ្នំនិងទេសភាពទាំងពួង ដែលកំដៅព្រះអាទិត្យរដូវប្រាំង កំទេចជាផង់ធូលីមើលយូរទៅនាងរោយភ្នែក នាងក៏ដាក់មុខសញ្ជឹងសញ្ជប់ ខ្យល់ល្បឿនរត់បក់បោកសក់នាងយោលរវិចៗ។

ឱគូសង្សារថ្មើមប្រមាត់ កម្មអ្វីមកកាត់ឲ្យព្រាត់ខ្វាយ

ពីថ្ងៃនេះទៅបែកចេញឆ្ងាយ ឱស្ដាយសែនស្ដាយ ស្ដាយខ្លួនក្មេង

ម៉ែអើយមានសីលនៅពេញខ្លួន ម្ដេចឲ្យកូនខ្លួនសោកសង្រេង

ម្ដេចហ៊ានផ្ដាច់កូនពីគូព្រេង វង្វេងនេះព្រាតតែក្ដីលោភ

ពាក្យកាព្យដែលនាងបានអានឃើញក្នុងសៀវភៅមួយ ក៏នៅថតជាប់ក្នុងសតិនាង។ លុះនាងត្រូវរងទុក្ខប្រកបគ្នានឹងលក្ខណៈនៃពាក្យនេះ ទំនុកឃ្លោងក៏រោយជ្រុះចេញមកដោយឯង។ តាំងតែពីនាងដឹងខ្លួនថា ម្ដាយលើកនាងឲ្យទៅថៅណៃស៊ិតកាលណាមក ទឹកមុខនាងក៏ចេះតែក្រៀមក្រំអាប់រស្មី។ បុប្ផាទាំងពួងដែលរីកស្គុះស្គាយជាលំអធម្មជាតិ បើត្រូវកំដៅព្រះអាទិត្យ ឬមានម្ចប់អ្វីមកគ្រួបដណ្ដប់ តែងនឹងស្រពោន រុះរោយចោលត្របកវាយនៅលើពសុធា យ៉ាងណាមិញ នារីដែលមានរូបឆោមលោមពណ៌ ដែលជាលំអនៃមនុស្សធម៌ តែកាលណាមានអាការអកុសលមកបៀតបៀន ក៏សឹងតែធ្លាក់ទៅក្នុងសភាវៈចង្រៃនោះ ដូចគ្នាដែរ។

នាងវិធារី គិតដល់ពាក្យដែលបានសន្យា គិតដល់សេចក្ដីស្នេហារបស់នាង គិតដល់រឿងរ៉ាវសៀវភៅប្រលោមលោក ដែលនាងបានអានខ្វះក្នុងអក្សរសាស្ត្រសៀមគិតដល់ប៊ុនធឿន ដែលនាងធ្លាប់ដឹងចិត្តដឹងថ្លើម គិតមមៃសព្វគ្រប់ទៅ នាងសល់សែនចំបែងក្នុងចិត្ត

អត្ថបទដោយ៖ មាស សុភាព

នាងយល់ម្តងថា ត្រូវជំរាបម្តាយនាង ពីការណ៍មិនចូលចិត្ត នឹងនាងថូព្រោះថាស្ត្រីនេះ ជាអ្នកវាយកំពស់ដោយអាងសម្បត្តិ និងពីដំណើរស្អប់ឈ្មោះណៃស៊ិត ដែលជាកំឡោះប្រហើនស្រវឹងដោយធនធាន មិនមានចិត្តមេត្តាករុណាដល់អ្នកតូចទាបឡើយ។ នាងគិតពន្យល់ម្តាយនាងថា ឈ្មោះណៃស៊ិតចង់បាននាងជាភរិយានេះ ដោយប្រាថ្នាត្រេកនឹងលំងរូបនាងប៉ុណ្ណោះ។ តែបើកាលណា នៅកពប្រសព្វគ្នាយូរទៅនាងនឹងមានកូនចៅ ឯរូបរាងក៏អន់ទ្រុឌទ្រោមទៅដែរ ឈ្មោះនេះក៏នឹងលះបង់ចោលនាងហើយ នាងនឹងលុះនៅក្នុងសេចក្តីតោកយ៉ាកពុំខាន។ តាមពាក្យអ្នកផងគេនិយាយថា ឈ្មោះណៃស៊ិត មានចំណូលនឹងបរទោកម្មណាស់ ហើយថែមទាំងបានធ្វើនារីម្នាក់ឲ្យមានគត៌ រួចហើយឈ្មោះណៃស៊ិតក៏បង់ប្រាក់កាស បន្តិចបន្តួចចោលស្ត្រីនោះមានទំនួលដូចគេបរិភោគគុយទាវ ឬកាហ្វេ ហើយចេញប្រាក់ឲ្យទៅអ្នកលក់យ៉ាងនោះឯង។ នឹកហើយនាងខ្សឹកខ្សួលតែនឹងហាមាត់ជំរាបម្តាយតាមយោបល់នេះមិនរួចដោយនាងជាយុវតីមួយស្រគត់ស្រគំ ធ្លាប់ពន្ធយកិរិយាមារយាទតាមលំអាននៃទំនៀមបុរាណចាស់ទុំជានិច្ច។ នាងមានសេចក្តីអៀនខ្មាសច្រើន មិនហ៊ានចរចាពីសេចក្តីស្នេហាសោះឡើយ ប្រការមួយទៀត នាងគិតឃើញថា សម័យនេះហួសឱកាសទៅហើយ ទោះនាងប្រកែករឹងរូសដូចម្តេចក៏មុខតែយាយទួនគាត់ប្រែសំដីថាទេវិញមិនបានឡើយ។ ខែពិសាខ! នៅតែមួយខែទៀតទេ...នឹកឃើញថាពេលអាពាហ៍ពិពាហ៍កិច្ចនៅខ្ជិដូច្នោះនាងក៏ព្រឺព្រួច ហើយសុំបួងសួងទេវតាឲ្យជួយយោងសេចក្តីស្នេហានាងឲ្យផុតពីគ្រោះធំនេះ។

ឡានបរទៅមុខ! ទៅមុខ! ...នេះប្រជុំជនមង្គលបុរី...នេះសេរីសោភ័ណ! អ្នកដំណើរក៏នាំគ្នាចុះស្រទៅប្រញិបប្រញាប់ទិញបាយចិនអាស្រ័យ។ យាយទួនគាត់ក៏ស្រាយកញ្ចប់ហើយកាច់នំបុ័ងមួយកំណាត់ និងបេះសាច់ក្រកមួយគួឲ្យទៅម៉ែផៃ ទើបគាត់ហៅកូនគាត់:

មកអារី ស៊ីនំបុ័ងទៅ។

នាងវិធាវី ក៏យកនំបុ័ងប៉ុនមេដៃបិទនឹងសាច់ក្រកមួយចំណិត។ ម្ហូបនេះហាក់ដូចជាមានឱជារសល្វីងចត់ផ្តេសផ្តាសក្នុងមាត់នាង។ នាងលេបមិនរួច ក៏ខ្ជាក់ចោលទៅនឹងថ្នល់។ ក្នុងវេលានោះមានឆ្កែខ្មៅមួយដែលមាន អង្គែស៊ីពេញខ្លួន ដើរមករើសកញ្ជាក់នាងវិធាវី ធក់បរិភោគហើយសំដែងទឹកមុខឲ្យឃើញថា ចំណីនោះឆ្ងាញ់ពិសាយ៉ាងចំឡែក។ នាងក៏កាច់

*នំប៉័ងមួយដុំប៉ុនកដៃបោះឲ្យទៅសុនខនេះទៀត។ សត្វនេះមុននឹងត្របាក់ចំណីនោះ ក៏លើកភ្នែកសំឡឹងមកនាង មានកិរិយាហាក់ដូចជាចង់ថ្លែងសេចក្ដីអរគុណចំពោះនាង! នាងវិធារីក៏កើតសញ្ជឹង: ឱសត្វតិរច្ឆាននេះ ចេះនឹកគុណ ឯមនុស្សម្ដេចក៏ភ្លេចសេចក្ដីសន្យាហ្ន៎?*

*អារី ម៉ែចក៏មិនញ៉ាំនំឲ្យច្រើនទៅ នៅជាងពាក់កណ្ដាលផ្លូវទៀតទើបដល់សៀមរាប។ ញ៉ាំទៅ តិចទៅជាខ្យល់ ជាព្យុះអីទៀតហើយ។*

*ចា៎ះ ម៉ែ ខ្ញុំមិនសូវឃ្លានទេ។*

*យាយនួនគាត់ក៏ងើបមើលភក្ត្រកូនគាត់ ហើយងាកចេញភ្លាមបែរសំឡឹងទៅទីឆ្ងាយ មានទឹកមុខព្រួយចំប្រប់ ទ្រូងគាត់តឹង ខ្លួនគាត់ស្រយង់។ គាត់គិតឃើញថា កិរិយាចំឡែកនៃកូនគាត់យ៉ាងនេះ ដល់មានគូគ្រងទៅមុខជានឹងផ្លាស់ប្ដូរវិញពុំខាន...គំនិតនេះធ្វើឲ្យយាយនួនធូរទ្រូង ព្រោះនៅជិតថ្ងៃខែណាស់ហើយ។*

***(សូមរង់តាមដានរឿង ផ្កាស្រពោន ភាគទី១១ នៅសប្ដាហ៍ក្រោយ)***

*អត្ថបទដោយ៖ មាស សុភាព*